ការសំភាសន៏របស់ លោកយាយ លុយ ព្រិច

ក៖ អ្នកធ្វើការសំភាសន៏ដោយ គីម ម៉េង ខ៖ អ្នកដែលត្រូវបានគេសំភាសន៏ លុយ ព្រិច

ប្រវត្តិសង្ខេបរបស់លោកយាយ លុយ ព្រិច

លោកយាយ លុយ ព្រិច គាត់មានអាយុ ៧៥ ឆ្នាំ ក្នុងឆ្នាំ ២០១៩។លោកយាយ លុយ ព្រិច មានទីលំនៅបច្ចុប្បន្ន នៅភូមិ មហាទេព សង្កាត់ ស្វាយជ៉ោយ ស្រុកបាត់ដំបង ក្រុងបាត់ដំបង។លោកយាយ លុយ ព្រិច មានកូនចំនួន ៦។

ខ៖
ភូមិភាគនិងគឺគេមិនដែរយកទៅរៃចោលនោះទេចាសហើយក៏មិនដែរយកទៅកសាងនោះដែរចាស ។
ក៖
អូចឹងបានន័យថាសំរាប់អ៊ុំនៅក្នុងជំនាន់មុនអ៊ុំរស់ខាងនេសាទមែនដែររឺទេអ៊ុំ ???
ខ៖ ចាសៗនៅខាងនេរសាទចាស។
ក៖ តែសំរាប់អ៊ុំមិនសូវពិបាកនោះទេមែរដែរទេអ៊ុំ ???
ខ៖ ចាសៗ មិនសូវជាពិបាកអីនោះទេ
ពីព្រោះអីនឹងសំរាប់ខ្ញុំដើរប្រមូលកន្តកយកមកសុីបានគ្រប់គ្រានចឹងហាសចាសវាមានតាមដំបន់ដែរគ្នាវាអត់នឹងហាសខាងខ្ញុំនិងវាអត់នោះទេគឺអាចហូបបានគ្រប់គ្រាន់សំរាប់បបរប្រសិនជាយើងមិនហូបតិចទៀតនិងគេអោយយើងបានបបរខាប់ដែរបបរនិងជាបបរឈ្លាលនិងយើយចែកគ្នាហូបទៅបានតែ៤ទៅ៥ថ្ងៃនិងមើលទៅវានឿយពេកនិងក៏គេនាំគ្នាស្ទើដើម្បីហូបបាយវិញចាស
ធ្វើយ៉ាងមិចយើងដោះស្រាយអោយគេបានមួយគ្រប់គ្រាន់ហើយសំរាប់ខាងនេសាទនឹងគេបានបញ្ជូនអោយគេនិងក៏មួយគ្រប់គ្រាន់ដូចគ្នាដែរដូចជាប្រហុកអំបិលអីចឹងទៅហាសចាស ហើយនឹងត្រីដៀតអីទៀតចឹងទៅ
បានថាមកសួរខ្ញុំនៅក្នុងជំនាន់និងខ្ញុំឆ្លងកាត់អត់មានអីនឹងគឺខ្ញុំនិងអត់មានរឿងអត់នោះទេចាសហើយប្រសិនជានៅខាងនេះបាក់ព្រៃបទន្លេរសាបយើងនេះដូចថាស្រុកកំណើតរបស់យើងនៅទឹកន្លែងនឹងគឺពួកវានឹងអោយយើងរស់នៅទឹកន្លែងនឹងតែម្តងអត់អោយយើងទៅណានោះទេ ។
ក៖ ចឹងវាស្រួលបែបលក្ខណៈជាងប្រជាជនផ្សេងមែនដែររឺទេអ៊ុំ ???
ខ៖ ចាសៗ
ហើយសំរាប់ពួកប៉ុលពតនឹងពួកវាធ្វើសង្គ្រាមទាំងយប់ទាំងថ្ងៃហើយពួកវានឹងបានដាក់ម៉ោងអោយយើងធ្វើការងារដូចជាធ្វើការម៉ោង១២
ថ្ងៃនិងធ្វើរហូតហើយយប់ឡើងគឺវាបានបួរវេនធ្វើការងារដល់ម៉ោង១២យប់បន្ថែមទៀតចាសនិយាយទៅគឺអោយធ្វើការនឹងមួយយប់ទាល់ភ្លឺគឺពួកវានឹងរៃសំរុកចឹងចាសហើយសំរាប់ការអត់ឃ្លាននិងគឺគ្រប់រហូតពីព្រោះអីគឺគេចេះតែផ្តល់អាហារនឹងមកអោយយើងរហូតចាសចឹងឯង ។
ក៖
បាទចឹងសំរាប់នៅក្នុងសម័យមុននឹងអ៊ុំមិនសូវជាពិបាកច្រើននោះទេមែនដែរទេអ៊ុំ ???
ខ៖ ចាសអ៊ុំមិនសូវជាពិបាកនោះទេកូន
តែមាននាក់ខ្លះនិងអត់មានអីសុីមានសំរាប់ក្បាលរបស់គេឡើងតាមែនៗនៅពេលដែរខ្ញុំបានជួបនឹងគឺខ្ញុំអោយសុីមួយឆ្អែតៗចាស ។
ក៖ បាទ
ហើយសំរាប់អ៊ុំកាល់នៅក្នុងជំនាន់ប៉ុលពតនឹងថាតើអ៊ុំរស់នៅទឹកន្លែងណាដែរទៅអ៊ុំ ???
ខ៖
ចាសខ្ញុំរសនៅទឹកន្លែងដ៏ដែរនឹងរស់នៅស្រុកនៅខាងបាក់ព្រៃងនឹងអត់មានរត់ទៅណានោះទេចាស
គឺស្នានទៅណានោះទេនៅពេលដែរវៀតណាមគេចុះមកនឹងគឺយើងបានចាប់ដៃគ្នាហើយរស់នៅស្រុកដ៏ដែរនឹងនៅខាងបាកព្រៃងនឹងគឺអត់មានការចែកអង្គរថ្ណានីនឹងគឺស្នានបានទៅណានោះទេចាសនិយាយរួមទៅគឺអត់មានបានទៅណានោះទេចាស ។

ក៖ បានសំរាប់អ៊ុំស្រួលដែរអត់ត្រូវគេជំលៀសទៅណានោះទេមែនដែររឺទេអ៊ុំ ???
ខ៖ ចាស ។
ក៖
បានហើយចឹងសំរាប់អ៊ុំនៅក្នុងសម័យប៉ុលពតអ៊ុំអត់មានធ្វើការងារដែរលំបាកដូចជាដកស្ពុងអីនឹងអ៊ុំអត់បានធ្វើការងារនឹងនោះទេមែនដែរទេអ៊ុំ ???
ខ៖ កាលនៅសម័យប៉ុលពតមែនដែរទេ ???
ក៖ បាទ ។
ខ៖
ចាសនិយាយទៅគឺគេបានប្រើយើងដែរអោយទៅដកនឹងតែពេលនឹងគឺគេបានអោយអ៊ុំនឹងទៅយាមស្បូរហាសចាសទៅនិងនឹងគឺគេអោយយើង៣ទៅ៤ថ្ងៃនឹងគឺគេបានបញ្ជូនយើងមកវិញដ៏ដែរចឹងហាសចាសវាគ្រាន់តែនៅខាងនោះវាចាល់ចឹងទៅគឺវាបានដកយើងនឹងទៅ៤ទៅ៥ថ្ងៃទៅវាអោយយើងនឹងមកវិញហើយ
ហើយវាអោយយើងនិងមកនេរសាទគ្រីវិញហើយចឹងហាសបានថាមួយរគ្គៗរបស់វានិង
ចាសនិយាយទៅគឺគេអោយយើងជួយគេបានមួយរយៈខ្លីអីនិងគេអោយមកវិញហើយកាប់ព្រៃ
ហើយនិយាយទៅគឺគេធ្វើចឹងទាំងអស់គគឺគេមិនអោយចាល់នោះទរទូទាំងប្រទេសតែម្តង ។
ក៖
បានចឹងបានន័យថានៅសមយ័មុនអ៊ុំជានាក់ចាប់ចែនរបស់ទាំងអស់មែនដែររឺទេអ៊ុំ ???
ខ៖
ចាសនិយាយទៅគឺខ្ញុំជានាក់លើកដាក់របស់របបទាំងគោនៗមានដូនជាប្រហុកហើយនិងផ្អក់មាំអីទាំអស់និង ចាសនិយាយទៅត្រីងៀត
ផ្អក់អីនឹងគឺយើងជានាក់រៀបចំទុកចំសំរាប់អោយគេចឹងហាសចាស ។
ក៖ បានហើយសំរាប់អ៊ុំចេះអក្សរដែររឺទេអ៊ុំ ???
ខ៖ ចាសសំរាប់ខ្ញុំអត់ចេះអក្សរនោះទេចេះតែការកស៊ីនោះទេចាស។
ក៖ បានចឹងសំរាប់អ៊ុំអត់ចេះអក្សរនោះទេ ???
ខ៖ ចាសអត់ចេះអក្សរនោះទេ ។
ក៖
បាននៅសម័យមុននិងឪពុកម្តាយរបស់អ៊ុំគាត់អត់បញ្ជូនអ៊ុំទៅរៀនទេមែនដែររឺទេអ៊ុំ ???
ខ៖
ចាសនិយាយទៅអត់នោះទេពីព្រោះអីនៅស្រុកឪពុកម្តាយរបស់ខ្ញុំគាត់ក្រណាស់ប្រសិនជាគាត់អោយខ្ញុំទៅរៀនឬនៗរបស់ខ្ញុំអត់មានអីហូបនោះទេ
ហើយយើងគ្រាន់តែទៅធ្វើការងារដោះស្រាយបញ្ហាដើម្បីអោយគាត់បានហូបហាសពីព្រោះអីនឹងម្តាយរបស់យើងនៅជំនាន់នឹងគឺគាត់ក្រណាស់ចាស ។
ក៖ បានហើយសំរាប់អ៊ុំមានកូនចំនួនប៉ុន្មាននាក់ដែរទៅអ៊ុំ ???
ខ៖ ចាសនិយាយទៅខ្ញុំនិងលេខតែមួយអង្គនឹងក៏ខ្លួមមិនចេះដែរ
ហើយខ្ញុំចង់រៀនធម៌ណាស់តែខ្ញុំមិនចេះអក្សរយើងចេះតែសង្ខំទៅណានិយាយទៅអ៊ុំមិនបានរៀនទេកូន ។
ក៖ បានចឹងស្តាយមែនទែនសំរាប់អ៊ុំចង់រៀនធម៌តែអ៊ុំអត់ចេះអក្សរនោះទេបាន ???
ខ៖
ចាសនិយាយទៅខ្ញុំនិយាយរឿងរបស់ខ្ញុំតិចចុះនៅក្នុងសម័យមុនក្រួសាររបស់ក្រម្តាយរបស់ខ្ញុំនឹងគឺគាត់បានជំពាក់ប្រាក់និងចំនួន ៨០០០ រៀលកាលសម័យពីដើមហើយគេបានមកប្តឹងពីព្រោះអីនឹងគឺខ្ញុំបានចេញមុខមកធានាហើយបានដើរចេញទៅសុីឈ្នួលគេចឹងហាសអាយុ១៥ឆ្នាំខ្ញុំបានចេញពីស្រុកដើម្បីទៅសុីឈ្នួលគេដោះបំណល់ទេសុីរហូតដល់អាយុ
២៥ឆ្នាំបានដល់កំណត់បានហ៊ានចូលមកស្រុកវិញចឹងហាសចាសនិយាយទៅគឺចេញទៅធ្វើការកម្មករដើម្បីយកលុយនឹងមកសងគេហាសចាស ។
ក៖ បានចឹងបានន័យថាអ៊ុំធ្វើការងារសំណង់មែនដែររឺទេលោកយាយ ???

ខ៖ ចាសនិយាយទៅគឺធ្វើការសំណងនៅខាងទន្លេសាប ហើយដូចជាម៉ាម ហើយនិងប្រហុកត្រីដៀតអីចឹងទៅហាសចាសពីព្រោះអីនឹងនៅស្រុកនិងគឺសំបូរត្រីច្រើនចឹងហាសចាស ។
ក៖
បាទចឹងបានន័យថាលោកយាយធ្វើអីក៏បានអោយតែបានលុយនិងដោះស្រាយដើម្បីអោយម្តាយមែនរឺទេលោកយាយ ???
ខ៖
ចានិយាយទៅធ្វើអីក៏បានអោយតែបានលុយជួយម្តាយចឹងហាសចាសហើយខ្ញុំធ្វើគ្រប់យ៉ាងគ្រប់អាយុ
២៥ឆ្នាំបានខ្ញុំចូលមកស្រុករិញជួបម្តាយរិញចឹងហាសចាសនៅពេលដែរខ្ញុំបានចូលមកស្រុកនិងគឺបាន១ឆ្នាំនឹងគឺគេបានចូលមកដណ្តឹងខ្ញុំចឹងហាសចាសនិយាយទៅគឺវែងឆ្ងាយណាស់ចាសនិយាយទៅគឺវេទនាខ្លាំងណាស់ហើយអោយខ្ញុំធ្វើអីក៏ខ្ញុំព្រមធ្វើដែរឬដើម្បីដោះបំណលអោយម្តាយ ។
ក៖
បាទចឹងបានន័យថាជីវិតរបស់យើងត្រូវតែមានភាពតស៊ូបើលយើងមិនមានភាពតស៊ូនោះទេជីវិតរបស់យើងនិងមិនបានមានសុភមង្គលនោះទេមែនដែររឺទេលោកយាយ ???
ខ៖
ចាសនិយាយទៅប្រសិនជាយើងមិនតស៊ូនោះទេយើងដួលហើយទាំងឪពុកហើយនិងម្តាយគឺគេនិងមើលងាយយើងហើយចាសហើយសំរាប់ខ្ញុំគឺខ្ញុំជានាក់ធានាអះអាងអោយពួកគាត់ចឹងហាសចាស ។
ក៖
បាទហើយចឹងសំរាប់ឪពុកហើយនិងម្តាយរបស់លោកយាយគាត់មានឈ្មោះអ្វីដែរទៅលោកយាយ ???
ខ៖ ចាសសំរាប់ឪពុកហើយម្តាយរបស់ខ្ញុំគាត់ឈ្មោះ យាយរុំ ហើយនិងតារឿន ។
ក៖ បាទហើយសំរាប់លោកទាំង២នាក់គាត់អាយុប៉ុន្មានហាយដែឬទៅលោកយាយ ????
ខ៖
ចាសនិយាយទៅពួកគាត់បានស្លាប់បាត់អស់ហើយបាទពីព្រោះអីនឹងគឺគាត់មានអាយុ ៨០ ទៅ ៩០ ឆ្នាំហើយចឹងហាសបាទ ៕
ក៖
បាទហើយចឹងសំរាប់គាត់បានស្លាប់នៅក្នុងសម័យសង្គ្រាមរឺក៏នៅសម័យនេះដែលទៅលោកយាយា ???
ខ៖ ចាសនិយាយទៅគឺគាត់បានស្លាប់នៅក្នុងសម័យសន្តិភាពហើយចឹងហាសចាស ៕
ក៖ បាទចឹងបានន័យថាគាត់បានស្លាប់នៅក្នុងសម័យមានសន្តិភាពហើយចឹងសំរាប់លោកយាយមានឈ្មោះអ្វីដែលទៅលោកយាយ ???
ខ៖ ចាសសំរាប់ខ្ញុំមានឈ្មោះថា លុយ ព្រិច ចាស ៕
ក៖
បាទហើយចឹងសំរាប់លោកយាយឆ្នាំនឹងថាតើលោកយាយមានព្រះជន្មប៉ុន្មានហើយដែលទៅលោកយាយ ???
ខ៖ ចាសសំរាប់ខ្ញុំមានអាយុ ៧៥ ឆ្នាំ ហើយចាស ៕
ក៖ ហូរខ្ញុំស្មានតែលោកយាយមានអាយុ ៦៧ ទៅ ៧៨ឆ្នាំអីនឹង ៕
ខ៖ ចាសអត់ទេគឺខ្ញុំអាយុ ៧៥ ឆ្នាំហើយចឹងហាសចាស ៕
ក៖ បាទមើលទៅលោកយាយក្មេងអត់ទាន់ចាស់នោះទេលោកយាយ ???
ខ៖
ចាសនិយាយទៅគឺខ្ញុំទើបតែចូលដាច់ខែវស្សានឹងគឺមិនទាន់នឹងចូលទេហាសចាសនៅមួយខែទៅពីខែទៀតចឹងហាសបានមួយទៅខែទៀតនឹងបានចូលខែវស្សាតែសំរាប់យើងនឹងនៅក្នុងអាយុ ៧៥ ឆ្នាំនឹងដ៏ដែលចឹងហាសចាស ៕
ក៖ បាទតែសំរាប់ឆ្នាំថ្មីរឺក៏ឆ្នាំចាស់ដែលទៅលោកយាយ ???
ខ៖ ចាសនិយាយទៅគឺឆ្នាំថ្មីនោះទេបានខ្ញុំនឹងចូល ៧៦ ចឹងហាសចាស ៕
ក៖ បាទចឹងលោកយាយអាយុ ៧៦ ឆ្នាំហើយឬ ???

ខ៖ ចាសនិយាយទៅគឺខ្ញុំចូលបានតែចិត្ត ២
ខែចឹងហាសចាសនិយាយទៅគឺចូលចិត្តខែចែត្រហើយបានប្រសាក់ហើយលូវនឹង
គឺអត់ទាន់ដាច់ខែចែត្រនោះទេចាសបានប៉ុន្មានខែទៀតនឹងបានចូលប្រសាក់ចឹ
ងហាសហើយយើងនឹងទើបតែបានចូលបាន ២
ខែប៉ុននឹងចឹងហាសចាសនិយាយទៅគឺវានៅតែក្នុងអាយុ ៧៥
ឆ្នាំនឹងដែលចឹងហាសចាស ៕
ក៖
បានហើយចឹងសំរាប់ស្វាមីរបស់លោកយាយគាត់មានឈ្មោះអ្វីដែលទៅលោកយាយ
???
ខ៖
ចាសនោះគឺប្តីរបស់ខ្ញុំនឹងហាសហើយគាត់ពិការលើកដាក់លើកដាក់នឹងហើយហើ
យគាត់បានលើសឈាមទៀតចឹងហាសចាសនិយាយទៅយើងលើកដាក់ៗហើយវេទ
នាចង់ស្លាប់ទៅហើយហាសចាសរវល់តែពីងកូននឹងហើយនឹងចៅនឹងទៅធ្វើជាក
ម្មករអោយគេចឹងទៅហើយើបានតិចតួចនឹងបានទិញបាយអោយគាត់ហើយគា
ត់ហូបបាយនឹងគឺមិនបានទៀតហើយបបរនឹងក៏អត់បានទៀតចឹងហាសហើយនិ
យាយទៅគឺចូលចិត្ត ៣ ខែ ទៅ ៤ ខែ
ហើយចឹងគឺអត់មានបាយហើយនឹងបបរនោះទេចាសនិយាយទៅគឺបានតែទឹក
ដោះគោនឹងនោះទេហើយសំរាប់ខោទឹកនោមទៀតចាសចឹងបានថាយើងមានភា
ពវេទនាខ្លាំងណាស់ចាសហើយយើងមានអ្វីប្រសិនជាយើងចង់ទៅពេទ្យនឹងលុះ
ក្រាតែយើងនឹងទៅមានលុយចឹងហាសចាសហើយប្រសិនជាយើងអត់មានលុយចឹ
ងយើងយកគាត់ទៅព្យាលបាលនឹងយ៉ាងមិចនឹងបានចឹងហាសចាស ៕
ក៖
បានហើយចឹងសំរាប់ប្តីរបស់លោកយាយគាត់ព្រះជន្មប៉ុន្មានហើយដែលទៅលោក
យាយ ???
ខ៖ ចាសនិយាយទៅគឺដូចតែគ្នាចឹងនោះទេចាសសំរាប់ខ្ញុំអាយុ ៧៥
ហើយគាត់ក៏អាយុ ៧៥ឆ្នាំដែលចឹងហាសចាស
ហើយយើងលើកដាក់គាត់លើកដាក់គាត់ចឹងទៅហើយយើងបានតែអាហារកំប៉ុង
នោះទេចាសហើយសំរាប់អាហារកំប៉ុងនឹងនៅពេលដែលយើងនឹងបានអោយគាត់
ពិសារនឹងគឺយើងមិនអោយគាត់នឹងហូបទាំងអស់នោះទេគឺយើងអោយគាត់តែ
កន្លះសំរាប់ហូបចឹងហាសចាសពីព្រោះអីនឹងនៅពេលដែលគាត់ហូបទៅច្រើននឹង
គឺគាត់អាចនឹងក្អួកមកវិញចឹងទៅហាសចាសនិយាយទៅគឺយើងធ្វើអ្វីនឹងក៏មិន
បានដែលគឺយើងមានតែលើកដាក់ៗគាត់តែប៉ុននឹងឯងចាស ៕
ក៖ បានតែសំរាប់លោកយាយបានយកគាត់ទៅមន្ទីពេទ្យហើយរីនៅលោកយាយ
???
ខ៖
ចាសនិយាយទៅគឺយើងយកទៅព្យាលបាលនឹងអស់ពីសមត្ថភាពហើយចឹងតែសំរា
ប់គាត់នៅតែប៉ុននឹងឯងចឹងហាសចាសនៅពេលដែលយើងយកគាត់ទៅស្ទេនខួ
លក្បាលនឹងគឺក្បាលរបស់គាត់គឺមានឈាមកក់មួយធំហើយមិនដឹងយ៉ាងមិច
នោះទេចាសតែដល់ពេលនេះចឹងទៅគឺគេបានអោយយើងនឹងទៅទិញថ្នាំហាស
នៅក្នុងមួយឆុតរបស់វានឹងគឺមានតែ ៥ អំពូលទេហាសចាស
ហើយសំរាប់តំម្លៃរបស់វានឹងគឺ ៥០ ដុល្លា ហើយវាមានតែ ៥ អំពូលទេហាសចាស
ហើយគេអោយយើងនឹងទិញ៣ឆុត ហើយសំរាប់៣ ឆុតនឹងគឺតំម្លៃរបស់វានឹងគឺ
១៥០
ដុល្លាចាសនិយាយទៅគឺយើងចាក់ហើយថ្នាំទៀតគឺមិនបាត់ហាសចាសនៅពេលដែ
លចាក់នឹងគឺនៅក្នុងពេទ្យសង្គ្រោះបន្ទាន់នឹងគឺអោយពេទ្យគាត់សង្គ្រោះគាត់ហា
សចាសហើយសំមរាប់ព្យាលបាលឪពុកនឹងគឺកូនទាំងអស់គ្នានឹងបានជំពាក់គេ
ច្រើនណាស់សំរាប់ឪពុករបស់វានឹងហាសចាសហើយប្រសិនជាខ្ញុំនឹងគឺខ្ញុំទៅបាត់
ហើយតែសំរាប់កូនទាំងអស់គ្នានឹងគឺគាត់សុទ្ធធ្វើយ៉ាងមិចសងគុណអោយឪពុក
ហើយនឹងម្តាយរបស់ពួកគាត់ចឹងហាសចាស ៕
ក៖
បានហើយចឹងសំរាប់លោកយាយបានរៀបការជាមួយនឹងលោកតានៅក្នុងឆ្នាំណា
លោកយាយមានបានចាំដែលរីទេលោកយាយ ???
ខ៖ ចាសគឺខ្ញុំបានរៀបការនៅក្នុងឆ្នាំ ១៩៧០ គត់ ចាស៕

កះ
បាទចឹងបានន័យថាសំរាប់លោកយាយបានរៀបការនៅក្នុងសម័យលុនណលមែនដែលរឺទេលោកយាយ ???
ខះ
ចាសនិយាយទៅគឺនៅក្នុងសម័យរដ្ឋប្រហារបាននាងជាមួយបានទម្លាក់រដ្ឋប្រហារ ៕
កះ
បាទ!ចឹងនៅសម័យលុនណលនិងអ៊ីស្រីបានរៀបការជាមួយអ៊ីប្រុសសម័យនិងចង់សួរទៅកាន់អ៊ីថាតើអ៊ីធ្វើយ៉ាងម៉េចដែរទើបបានជួបជាមួយនឹងអ៊ីប្រុសដែរហើយបានរៀបការជាមួយនិងគ្នាដែរអ៊ី?
ខះ
ចាស!!នៅស្រុកជាមួយគ្នាម្តាយរបស់គេជាអ្នករើសអោយគ្មានរើសណានៅក្រៅពីស្រុកឯងបងប្អូនជីដូនមួយជីទួតមួយអីនិងឯង៕
កះ បាទ!!បាទចឹងបានន័យថាអ្នកភូមិនៅជិតជិតស្គាល់គ្នាណេះអ៊ីណេះ?
ខះ ចាស៕
កះ
បាទ!!ហើយសម័យមុនអ៊ីប្រុសបានអោយថ្លៃបណ្តាការអ៊ីប៉ុន្មានដែរអ៊ីពេលដែររៀបការ?
ខះ ចាសដូចអ៊ីបានប្រាប់អញ្ចឹងថា៨០០០ប្រាក់ពីដើមមិនធម្មតាទេណាស់៕
កះ បាទ!!៕
ខះ ចាសហើយ៨០០០ប្រាក់ពីដើមមាសតែមួយជីជិត៣០០គិតមើលមើល៕
កះ អ៎...ជិត៣ដំឡឹងណេះអ៊ីណេះអ្វូច្រើនណាស់?
ខះ ចាសចាស!!ស៊ីដាច់ដឹងម៉ែខ្ចំស៊ីដាច់ដឹងម៉ងគ្មានអោយមួយកាក់មួយសេនទេ៕
កះ អ៊ឹម...៕
ខះ ចាស!!ហើយមួយជី៣០០៕
កះ បាទ!!មួយជី៣០០មួយដំឡឹង៣០០០ចឹង២៥០០បានពីរដំឡឹងជិតបីដំឡឹង៕
ខះ ចាស!!៕
កះ អ៊ីលុយសម័យនិងគេចាយលុយអ្វីដែរអ៊ី?
ខះ ចាស!!លុយក្រដាសគេ៕
កះក្រដាសគរ ក្រដាសធំៗ?
ខះ ចាសក្រដាសធំៗក្រដាសលីឡងហិហិហិ..៕
កះហិហិហិ...អូខេ..ហិហិហិ..បាទលោកយាយរបស់ខ្ចំបានបន្សល់ទុកលុយក្រដាសធំៗនិងអោយចៅៗរបស់គាត់មើលដែរ៕
ខះ ចាស!!និងហើយ៕
កះ បាទ!!
តែខ្ចំអត់ដឹងថាសម័យណាសម័យណាខ្លះទេដោយសារលោកយាយរបស់ខ្ចំបានខូចចែកហានតាំងពីគាត់មានបព្រះជន្ម៧៣ឆ្នាំហើយដោយសារគាត់ជក់ជាវីច្រើនពេកហើយដល់ពេលដែរយកគាត់ទៅពិនិត្យសួតគាត់សល់ប៉ុនមេដៃ៕
ខះ ចាសនិងឯង៕
កះ
បាទ!!និងហើយមកពីគាត់ពិសារជាវីច្រើនពេកដោយសារកាលពីសម័យមុនគាត់បានឆ្លងកាត់ពីសម័យដែរលំបាកហើយចឹងទៅគាត់ចេះតែខូចចិត្តបងប្អូនគាត់ត្រូវគេយកទៅសម្លាប់ចោលអស់ច្រើនចឹងហាសអ៊ីដល់ចឹងទៅគាត់ចេះតែពិបាកចិត្តនឹកបងប្អូនអីចឹងទៅចេះតែខូចចិត្តចឹងទៅគាត់ជក់ជាវីហូបស្រាគិចតួចចឹងហាអ៊ីហើយដល់ពេលនាំគាត់យកទៅពេទ្យចឹងទៅពេទ្យថាមកការដែរគាត់ជក់ជាវីហូបស្រានិងធ្វើអោយខ្យល់ផ្សែងជាវីនិងចេញចូលនៅក្នុងសួតនិងចឹងទៅធ្វើអោយសួតគាត់នៅសល់ប៉ុនមេដៃចឹងគាត់ខូចតាំងពីគាត់មានព្រះជន្ម៧៣ឆ្នាំម្ល៉េះស្តាយតែគាត់បានបន្សល់ទុកលុយក្រដាសធំៗនិងច្រើន៕
ខះចាស!!ក្រដាសគរក្រដាសលីឡងហើយនិយាយទៅគឺគេដំកលក្អកចឹងហាសហើយគេមានពន្ធត់សចាសហើយនិយាយទៅគឺគេមាននាក់ដែលច្រូតស្រែចឹងហាសហើយគេទុក្ខតែ ២ ទៅ ៣
ឆ្នាំចឹងហាសហើយសំរាប់យើងនឹងគឺទុក្ខរបស់នឹងគឺមិនដាយនឹងគឺខួចនោះទេចាស ៕

ក៖
បាទហើយសំរាប់នៅក្នុងសម័យនឹងគឺលុយរបស់យើងនឹងគឺស្អាតៗណាស់មែនដែលរឺទេលោកយាយ ???
ខ៖
ចាសនិយាយទៅគឺលុយរបស់គេនឹងគឺស្អាតខ្លាំងណាស់ហើយសំរាប់លុយជំនាន់មុននឹងគឺគ្មាននាក់ណាយកទៅចាយនោះទេគឺគេយកទៅកើលសំរាប់ដេកចឹងហាសចាសនៅពេលដែលគេយកឆែតនឹងគឺគេយកទៅប្តូរប្រែម៉ាស៊ីនប្រែនអីចឹងហាសចាសនិយាយទៅគឺគេហៅយើងនឹងទៅឆែតយកតែម្តងចឹងហាសចាស ៕
ក៖
បាទហើយចឹងសំរាប់យើងនៅក្នុងជំនាន់នឹងថាតើយើងចាំបាច់ហៅទៅប្តូរធ្វើអ្វីទៅលោកយាយ ???
ខ៖
ចាសនិយាយទៅគឺគេបានហៅយើងនឹងទៅឆែតប្តូរប្រែម៉ាស៊ូតអីចឹងទៅហាសចាសហើយតែយកលុយនឹងទៅខាងណាខាងណីអីនឹងគឺយើងមិនបានដឹងនោះទេចាស ៕
ក៖
បាទនិយាយទៅគឺគេមិនបានអោយយើងនឹងទៅវិញនោះទេមែនដែលរឺទេលោកយាយ ???
ខ៖
ចាសនិយាយទៅគឺគេមិនបានអោយយើងនឹងបានមកវិញនោះទេបាទហើយសំរាប់មាសនឹងគឺយើងមានប៉ុន្មានគឺគេនឹងយករបស់យើងទាំងអស់ចឹងហាសហើយសំរាប់គេនៅពេលដែលគេយកហើយនឹងគឺគេមិនបានអោយយើងងនឹងវិញនោះទេចាសនិយយាទៅគឺយើងមិនអាចទុក្ខបាន១ហ៊ុនមួយលីនឹងគឺមិនបាននោះទេនិយាយទៅគឺមានតែប៉ុននឹងចឹងហាសចាសនិយយាប្រសិនជាយើងមានអ្វីនឹងគឺគេបានដកយកទាំងអស់ចឹងហាសហើយគឺយើងមានតែខ្លួនរបស់យើងនោះទេចាសហើយសំរាប់អង្គការនឹងគឺដើរសុំបាយគេស៊ីចឹងទៅគឺគេបានអោយយើងនឹងស៊ីចឹងហាសហើយគេមិនបានអោយយើងនឹងអត់នោះទេនិយាយទៅគឺគេមិនអោយយើងនឹងរហែងរហាមនោះទេចាសនិយាយទៅគឺយើងមានមាសនឹងតាំងពីសម័យសម្តេចមកម្លេះចឹងហាសចាសហើយនៅពេលដែលយើងនឹងបានចូលមកភូមិភាគនឹងគឺគេបានដកយកអស់ហើយចឹងហាសចាស ៕
ក៖
បាទនិយាយទៅគឺដោយសារយើងបានយកមាសនឹងទាំងអស់នឹងយកទៅប្តូរជាប្រែហើយនឹងអង្ករមែនដែលរឺទេលោកយាយ ???
ខ៖
ចាសនិយាយទៅគឺត្រូវហើយគឺយើងបានប្តូរជាអង្ករហើយនឹងប្រែហើយសំរាប់យើងប្រសិនជាយើងចង់បានរបស់ទាំងអស់នឹងក៏យើងនឹងមិនបានរស់នៅបានដែលចឹងហាសហើយពីព្រោះអីនឹងគឺយើងនឹងអាចស្លាប់ចឹងហាសចាសនិយាយទៅគឺយើងក៏មិនយកចឹងហាស
ហើយនិយាយទៅគឺគេសំលាប់យើងចឹងហាសចាសនឹងប្រសិនជាយើងមិនបានអោយទៅគេចឹងហាសហើយគេបានគំរាមយើងថាប្រសិនជាយើងចង់ទុក្ខរបស់ទាំងអស់នឹងរ៉ូមួយក៏ចង់ទៅរស់នៅស្រុកអត់មានតែម្តងហើយសំរាប់ស្រុកមួយនឹងគឺជាស្រុករបស់ខ្មោចចឹងហាសចាសហើយសំរាប់យើងនឹងគឺយើងមិនអាចទៅនៅទីកន្លែងណាបាននោះទេសំរាប់មួយនឹងចឹងហាសចាស ៕
ក៖
បាទហើយចឹងបានជាយើងនឹងសុខចិត្តអោយរបស់ទាំងអស់នឹងទៅគេមែនដែលរឺទេលោកយាយ ???
ខ៖
ចាសនិយាយទៅគឺយើងសុទ្ធអោយទៅគេទាំងអស់ចឹងហាសហើយធ្វើយ៉ាងមិចនឹងអោយតែយើងនឹងបានរួចខ្លួនចឹងហាសចាសហើយបានអង្គការនឹងគឺគេបានយកយើងនឹងទៅហើយអោយទៅធ្វើជានាក់ដែលនេសាទចឹងហាសហើយបានយើងនឹងបានរួចខ្លួនចឹងហាសចាសនិយាយទៅគឺគេបានអោយយើងនឹងទៅធ្វើនេសាទត្រីហើយសំរាប់នាក់ដែលនៅខាងនឹងគឺគេមិនបានអោយយើងនឹងអត់នោះនឹងគឺរ៉ាចឹងហាសចាស ៕

កះ៖
បាទនិយាយទៅសំរាប់លោកយាយដែលចាស់ពីមុនៗនឹងគឺគាត់បានខំប្រឹងនឹងសន្សំខ្លាំងមែនទែនគឺគាត់បានសន្សំទាំងលុយហើយនឹងសន្សំទាំងមាសចឹងហាសហើយមិនថាលោកយាយរបស់ខ្ញុំនឹងគឺគាត់ក៏ចឹងដែលហើយចឹងគឺគេបានដកយកទាំងអស់នឹងចឹង
ហើយនៅពេលដែលស្រុករបស់យើងនឹងគឺមានសង្គ្រាមនឹងគឺគេបានប្លន់លុយទាំងអស់មែនដែលរឺទេលោកយាយ ???
ខះ៖
ចាសនិយាយទៅនៅពេលដែលស្រុកមានសង្គ្រាមនឹងគឺគេបានផ្លាស់ប្តូរយកទាំងអស់ចឹងហាសចាសហើយសំរាប់ពេលដែលបានផ្លាស់ប្តូរនឹងគឺគេចង់យកអ្វីនឹងក៏បានដែលចឹងហាសពីព្រោះអីនឹងគឺយើងនៅក្រោមអំណាចរបស់គេចឹងហាសចាស ៕
កះបាទហើយចឹងសំរាប់កូនរបស់លោកយាយមានគ្នាចំនួន ៥ នាក់មែនដែលរឺទេលោកយាយ ???
ខះ៖ ចាសសំរាប់កូនរបស់ខ្ញុំគឺមានគ្នាចំនួន ៦ នាក់ចាស ៕
កះ៖
បាទហើយចឹងសំរាប់ពួកគាត់ថាពួកគាត់មានគ្រួសារអស់ហើយមែនដែលរឺទេលោកយាយ ???
ខះ៖
ចាសគឺពួកគាត់មានគ្រួសារអស់ហើយនិយាយទៅគឺនៅសល់តែចៅដែលរស់នៅជាមួយនឹងយើងចឹងហាសចាស ៕
កះ៖
បាទហើយចឹងសំរាប់លោកយាយថាតើលោកយាយមានចៅទួតហើយរឺនៅលោកយាយ ???
ខះ៖ ចាសគឺខ្ញុំអត់មានចៅទួតនោះទេចាស ៕
កះ៖
បាទហើយចឹងសំរាប់ចៅបង្កើតថាតើលោកយាយមានចៅប៉ុន្មាននាក់ដែលទៅលោកយាយ ???
ខះ៖ ចាសសំរាប់ចៅបង្កើតរបស់ខ្ញុំនឹងគឺមានគ្នាប្រហែលជា ៣ ទៅ ៤ នាក់ចឹងហាសហើយសំរាប់ពួកវានឹងគឺនៅស្ទើរនោះទេចាសពីព្រោះអីនឹងគឺពួកវានឹងគឺមានអាយុ ១៤ ទៅ ១៥ ឆ្នាំនោះទេចាស ៕
កះ៖ បាទចឹងបាននិយាយថាសំរាប់លោកយាយប្រហែលជា ១០ ទៀតនឹងលោកយាយមានចៅទួតហើយមែនដែលរឺទេលោកយាយ ???
ខះ៖ ចាសៗ ហើយសំរាប់យើងក្រចឹងគ្មាននាក់ណាមកស្រឡាញ់យើងនោះទេចាស ៕
កះ៖
បាទតាមពិតការស្រឡាញ់គ្នានឹងគឺគេមិនគិតចឹងហាសហើយសំរាប់គេក៏មានដៃហើយយើងក៏មានដៃហើយសំរាប់គេមានជើងយើងក៏មានជើងហើយយើងអាចរកបានដូចគ្នាចឹងហើយគេមិនប្រកាន់យើងនោះទេមែនដែលរឺទេលោកយាយ ???
ខះ៖
ចាសនិយាយទៅសំរាប់កូនឯងបានគិតចឹងសំរាប់យើងក្រហើយគ្មានលុយកាក់អីទាំងអស់នឹងជួនកាល់នឹងក៏គេមិនបាននឹងខ្វល់នឹងយើងដែលចឹងហាសចាសទោះបីជាមាយាតរបស់យើងនឹងបានប៉ុន្មានក៏ដោយក៏គេនឹងមិនបានមកខ្វល់ជាមួយនឹងយើងដែលចឹងប្រសិនជាយើងអត់មានលុយកាក់ខ្លះហាសចាសហើយសំរាប់នាក់មានប្រសិនជានាក់នឹងគេខុសយ៉ាងណាក៏ដោយហើយគេលើសត្រូវអីក៏ដោយហើយប្រៀបធ្រៀបថាគេអស់សាច់ក៏ដោយតែសំរាប់គេគឺគេមានលុយក៏តែគេមាននាក់ដែលចង់បានដែលចឹងហើយសំរាប់យើងដែលជានាក់ក្រនឹងគឺយើងទៅមិនរួចនឹងគេនោះទេចាសហើយទោះបីជាទៅមិនកើតយ៉ាងណាក៏ដោយចឹងហាសចាសពីព្រោះអីនឹងគឺយើងអត់មានលុយមានកាក់សំរាប់ចែកគេចឹងហាសចាស ៕
កះ៖
បាទនឹងហើយបាននិយាយថាចូលលក្ខណៈថាគេមើលងាយយើងខ្លះៗហើយមែនដែលរឺទេលោកយាយ ???
ខះ៖ ចាសនិយាយទៅគឺគេមើលងាយហាសចាស ៕

កៈ
បាទតែអ្វីដែលសំខាន់នឹងគឺខ្លួនរបស់យើងនោះទេដែលយើងបានផ្តល់តំលៃអោយខ្លួនរបស់យើងហើយនឹងតស៊ូហើយយើងនឹងមាននៅថ្ងៃណាមួយមែនដែលរឺទេលោកយាយ ???
ខៈ
ចាសនិយាយទៅសំរាប់មនុស្សខ្ញុំនឹងថាកុំអោយមើលងាយមនុស្សចឹងហាសហើយកុំតែថ្ងៃណាមួយនឹងគឺយើងនឹងមានដូចគេដែលចឹងហាសចាសហើយជួនកាល់នឹងនាក់មាននឹងគឺគេមានមែនតែសំរាប់ថ្ងៃស្អែកនឹងគឺគាត់នឹងទៅជាក្រវិញចឹងហាសហើយនិយាយទៅគឺយើងមើលងាយគេនឹងមិនបានចឹងហាសចាសនិយាយទៅសំរាប់ខ្ញុំមិនដែលចេះនឹងមើលងាយគេនោះទេចាស ៕
កៈ
បាទនិយាយទៅដូចលោកយាយបាននិយាយចឹងហាសជីវិតរបស់យើងនឹងគឺយើងមើលមិនឃើញនោះសំរាប់ថ្ងៃណានឹងគឺយើងមានសំណាងអីចឹងទៅគឺយើងបានក្លាយទៅជានាក់មានក៍យើងមើលមិនដឹងដែលមែនដែលរឺទេលោកយាយ ???
ខៈចាសៗ ៕
កៈ
បាទនឹងហើយនៅពេលដែលគេបានទៅជានាក់មានហើយចឹងគឺគេនឹងបានរាប់យើងវិញហើយមែនដែលរឺទេលោកយាយ ???
ខៈ
ចាសនិយាយទៅសំរាបខ្ញុំក្រនឹងខ្ញុំនឹងធ្លាប់ដែលហើយសំរាប់ខ្ញុំមាននឹងក៍ខ្ញុំធ្លាប់មានដែលចឹងហើយចង់នាក់ឯងចង់និយាយយ៉ាងមិចក៍និយាយទៅតាមនឹងចឹងទៅហាសចាសហើយសំរាប់នាក់មាននឹងគឺមានលក្ខណៈនឹង២៤ម៉ោងនោះទេទោះបីជាយើងមានប៉ុន្មានក៍ដោយក៍យើងនឹងត្រូវតែអស់ចឹងហាសចាស និយាយទៅ ២៤ ម៉ោង
នឹងមិនទាន់នោះទេប្រសិនជាមានហេតុនឹងផលនឹងចឹងហាសគឺយើងនឹងអស់ហើយចាសនិយាយទៅគឺយើងមើលទៅគឺមិនទៀងទាត់នោះទេចាសចៅឯងគិតមើលទៅចឹងហាសាចាសហើយនិយាយទៅសំរាប់ចៅរបស់ខ្ញុំនឹងគឺគាត់បានលក់ចេកអាំងនៅមុខពេទ្យហាសនិយាយទៅវាលក់នៅមុខពេទ្យធំហាសចាស ៕
កៈ
បាទនិយយាទៅសំរាប់អ្នកមីងម្នាក់មុននឹងគឺគាត់ជាកូនរបស់លោកយាយមែនដែលរឺទេលោកយាយ ???
ខៈ ចាសនិយាយទៅគឺវាកូនរបស់ខ្ញុំចឹងហាសចាស ៕
កៈ បាទហើយចឹងសំរាប់គាត់មានអាយុប៉ុន្មានឆ្នាំហើយដែលទៅលោកយាយ ???
ខៈ ចាសសំរាប់វានឹងគឺអាយុ ៥០ ឆ្នាំហើយចាស ៕
កៈ បាទចឹងបាននយថាសំរាប់កូនរបស់លោកយាយគាត់អាយុ ៥០ ឆ្នាំហើយហើយគាត់បានឆ្ងង់កាត់នៅក្នងសម័យប៉ុលពតហើយមែនដែលរឺទេលោកយាយ ???
ខៈ
ចាសនិយាយទៅគឺវាអត់បានឆ្ងងកាត់នោះទេនៅក្នងជំនាន់នឹងគឺវានឹងនៅជាកុមារនោះទេចាសហើយនិយាយទៅគឺវានឹងគេបានអោយវានឹងបានធ្វើស្រូវធ្វើស្រែអីនឹងបានតិចតួចឹងហាសចាសសំរាប់នៅក្នងជំនាន់នឹងចឹងហាសចាសហើយនៅពេលដែលគេបានអោយវានឹងធ្វើចឹងគឺយើងនឹងបានទៅតាមមើលហើយនឹងខ្លាចគេវែរាវែអីចឹងទៅហាសចាស
ហើយដល់ពេលចឹងគឺយើងនឹងបានហៅពួកវានឹងអោយនៅខាងកុមារអោយពួកវានឹងបានចេះធ្វើត្រីចឹងហាសចាសហើយនិយាយទៅសំរាប់ក្មេងសម័យនឹងគឺពួកវានឹងកើតមិនទាន់នោះទេសំរាប់ជំនាន់នឹងចឹងហាសចាសហើយសំរាប់ជំនាន់គឺវានឹងទាន់ដែលតែសំរាប់នឹងទាន់នៅតូចចឹងហាសចាសអាយុ១១ឆ្នាំអីនឹងគឺគេបានអោយទៅរៀនដាក់ក្រាន់ស្រូវអីចឹងទៅហាសចាសនឹងនៅក្នងសម័យប៉ុលពតនឹងហាសហេហេហេចាស ៕
កៈ
បាទហើយចឹងខ្ញុំចង់សួរលោកយាយបន្តិចថាតាំងពីលោកយាយនៅតូចហើយរហូតដល់លោកយាយមានគ្រួសារហើយមានកូននឹងចំនួន ៦ នាក់ទៀតហើយសំរាប់លោកយាយចិញ្ចឹមកូនរបស់លោកយាយថាតើលោកយាយ

មានភាពលំបាកអ្វីខ្លះដែលទៅលោកយាយអាចប្រាប់យើងបានបន្តិចបានដែលរឺទេលោកយាយ ???
ខ
ចាសននិយាយទៅគឺថាយើងនឹងពិបាកនោះគឺពិបាកខ្លាំងណាស់ទៅហើយចឹងហាសហើយពីព្រោះអីនឹងគឺយើងបានជួយថែរក្សាកូនរបស់យើងទាំងអស់និយាយទៅគឺពិបាកនឹងមហាពិបាកពីព្រោះអីនឹងគឺយើងអត់មានដើមហើយនឹងចុងចឹងហាសចាសសំរាប់យើង២នាក់ប្តីហើយនឹងប្រពន្ធនឹងគឺយើងបានទៅចងដងសន្ទួចហើយធ្វើចេះទៅហាសហើយដើម្បីបានចិញ្ចឹមជីវិតរបស់យើងចឹងហាសនិយាយទៅគឺយើងនឹងពិបាកទៅហើយពីព្រោះអីនឹងស្រុកទន្លេរនឹងគឺយើងមានតែប៉ុននឹងទៅហើយណាកូនហើយនិយាយទៅគឺយើងនិយាយទូទៅចឹងហាសហើយសំរាប់កូនរបស់ខ្ញុំនឹងម្នាក់មួយមីបងនឹងហាសគឺខ្ញុំបានដាក់វានឹងនៅកណ្តាលទូតហើយនឹងបានជាំងឆ័ត្រហើយអ៊ុចឹងទៅហាសជាមួយនឹងប្តីហើយនឹងចងសន្ទួចពីព្រោះអីនឹងគឺយើងជានាក់ក្រហើយនឹងទៅរកកាប៉ាលសំរាប់បើកនឹងទៅរកមកពីណាចាសហើយយើងចេះតែទៅចឹងទៅដើរពាក់ម៉ងហើយនឹងចងសន្ទួចអីចឹងទៅហាសហើយសំរាប់កូនមីបងគេនឹងម្នាក់នឹងគឺវានឹងពិបាកជាគេហាសហើយកូនរបស់ខ្ញុំមុននឹងចឹងហាសចាសដែលវានឹងមានអាយុ ៥០
ឆ្នាំចឹងហាសហើយវាលក់ចេកអាំងនៅមុខពេទ្យធំនឹងហាសចាស ៕
ក៖ បាទហើយចឹងសំរាប់លោកយាយគិតថាសំរាប់កូនរបស់លោកយាយទាំង ៦ នាក់នឹងថាតើមាននាក់ដែលលោកយាយគិតថាពិបាកនឹងចិញ្ចឹមជាងគេដែលទៅលោកយាយ ???
ខ៖
ចាសនិយាយទៅគឺយើងដឹងហើយសំរាប់នៅក្នុងជំនាន់នឹងគឺគ្មាននាក់មានជាងនាក់នោះទេសំរាប់ការអត់មានអ្វីសំរាប់ហូបចឹងហាសហើយសំរាប់ខ្ញុំនឹងគឺខ្ញុំចេះតែមានគុណបុណ្យចេះតែជួយខ្ញុំរហូតចឹងហាសចាសនៅពេលដែលខ្ញុំបានទៅក្រៅនឹងគឺខ្ញុំចេះតែបានត្រីហើយនឹងសាច់នឹងបានមកប្រឡាក់ហើយនឹងបានយកទៅលក់ចឹងទៅហាសចាសហើយនិយាយទៅគឺខ្ញុំបានទៅលក់នឹងក្នុងមួយថ្ងៃនឹងគឺបាន ១០០០០រៀល ទៅ ២០០០០រៀល
អ៊ីចឹងទៅហាសាចាសហើយសំរាប់ពេលយប់នឹងគឺខ្ញុំបានចងសន្ទួចនឹងបាន ១០០០០ រៀល ទៅ ២០០០០រៀល
ចឹងទៅហើយបានចឹងទៅគឺយើងចេះតែយកមកសន្សំដើម្បីទៅទិញជាអង្ករទៅចឹងហាសចាសនិយាយទៅគឺគ្មាននាក់ណាល្អជាងនាក់នោះទេពីព្រោះអីនឹងគឺយើងស៊ីអង្ករគឺឡរទាំងអស់គ្នាចឹងហាសចាសនិយាយទៅគឺគ្មាននាក់ណាល្អជាងនាក់ណានោះទេសំរាប់នៅក្នុងសម័យនឹងចឹងហាសចាស ៕
ក៖ បាទហើយចឹងសំរាប់កូនរបស់លោកយាយទាំង ៦ នាក់
ថាតើគាត់បានទៅរៀនសូត្រទាំងអស់គ្នាដែលរឺទេលោកយាយ ???
ខ៖ ចាសនិយាយទៅគឺរៀនបានតែ ២
នាក់នោះទេហើយសំរាប់ស្រីម្នាក់នឹងគឺគាត់បានប្រលងនឹងបានជាប់ថ្នាក់ ១២ ជាប់ចឹងហាសចាសតែសំរាប់ខ្ញុំអត់មានលុយអោយពួកវានឹងបានទៅរៀនបានបន្តទៀតនឹងក៏ខ្ញុំនឹងបានអោយពួកវានឹងបានឈប់រៀនចឹងទៅហាសចាសនិយាយទៅគឺគេមានសញ្ញាប័ត្រនឹងទី១២របស់គេនឹងបានត្រឹមត្រូវហាសចាសហើយចឹងខ្ញុំក៏បានអោយគេនឹងបានឈប់រៀនចឹងទៅហាសចាហើយសំរាប់ពេលនឹងគឺខ្ញុំបានមករស់នៅស្រុកបាត់ដំបងនឹងហើយហាសចាសហើយនៅពេលដែលយើងនឹងបានមកបាត់ដំបងនឹងខ្ញុំបាននៅតាមចិញ្ចើមផ្លូវហើយនឹងនៅតាមសាលារៀនដើម្បីអោយកូនបានរៀន ៕
ក៖
បាទហើយចឹងបាននៃយថាសំរាប់លោកពូគាត់គឺជាកូនរបស់លោកយាយដែលមែនដែររឺទេលោកយាយ ???
ខ៖ ចាសសំរាប់វានឹងក៏ជាកូនរបស់ខ្ញុំដែលចឹងហាសចាស ៕
ក៖ ចឹង ???
ខ៖
ចាសនិយាយទៅគឺវានឹងបានបន្ទាប់ពីមីបងរបស់វានឹងហាសចាសហើយសំរាប់វានឹងគឺឆ្នាំ ថោះ ៕

កៈ បាទហើយចឹងបានន័យថាសំរាប់គាត់នឹងគឺមានអាយុ ៥០
ឆ្នាំជាដែលមែនដែលរឺទេលោកយាយ ???
ខៈ ចាសនិយាយទៅគឺវាអាយុតែ ៤០
ឆ្នាំជាងនោះទេចាសហើយសំរាប់វានឹងគឺវាបន្ទាប់ពីបងស្រីរបស់វានឹងហាសចាស
ហើយសំរាប់យើងបានសុំឆ្កែហើយនឹងបានដាក់បាយអោយវាស៊ីចឹងហាសហើយវា
បានស្លាប់ទទេៗចឹងហាសហើយសំរាប់ល្ងាចមិញនឹងគឺអាណិតវាខ្លាំងណាស់នៅពេ
លដែលយកវានឹងគឺយើងបានយកវាអោយទៅគេដើម្បីចិញ្ចឹមចឹងហាសចាស ៕
កៈ បាទចឹងដោយសារច្រើនពេកមែនដែលរឺទេលោកយាយ ???
ខៈ
ចាសនិយាយទៅគឺវាមាន២ឆ្កែនឹងហាសចាសតែគ្រាន់តែថាឆ្កែនឹងគឺវាពូកែខ្លាំង
ណាស់ហើយសំរាប់ម៉ូតូនឹងនៅពេលដែលយើងបានដាក់ចោលចឹងគឺគ្មាននាក់ណា
ហើយមានមីមួយដែលដេកនៅលើម៉ូតូនឹងហើយមីមួយទៀតនឹងគឺវាបានដេក
នៅកែបមួយយប់ទាល់ភ្លឺតែម្តងចឹងហាសហើយសំរាប់នាក់ណាដែលដើរកាត់នឹងក៏
មិនបានដែលហាសចាស ៕
កៈ បាទនិយាយទៅគឺវាឆ្លាតខ្លាំងម្លេះលោកយាយ ???
ខៈ
ចាសនិយាយទៅគឺគ្មាននាក់ណាដើរកាត់បាននោះទេហើយប្រសិនជាដើរនឹងគឺពួ
កវានឹងបានព្រុះហាសហើយសំរាប់២ក្បាលនឹងហាសចាសហើយនិយាយទៅគឺគ្មាន
នាក់ណាដែលអាចនឹងចូលមកផ្ទះបាននោះទេចាសហើយសំរាប់យប់ឡើងនឹងនៅ
ពេលដែលម្ចាស់របស់វានឹងបានឡើងទៅដេកនឹងគឺវាបានឡើងទៅដេកនៅលើម៉ូ
តូហើយនៅយាមនៅកន្លែងនឹងហាសចាសហើយសំរាប់មួយនឹងគឺពួកវានឹងបាន
ដេកនៅកែបម៉ូតូចឹងហាសចាស ៕
កៈ បាទហើយចឹងសំរាប់លោកយាយបានបង្រៀនពួកវាមែនដែលរឺទេលោកយាយ
???
ខៈ
និយាយទៅគឺម្ចាស់របសវានឹងបានបង្ហាត់ដោយខ្លួនឯងនឹងហាសចាសនិយាយ
ទៅសំរាប់ឆ្កែនឹងគឺជាពូជឆ្កែដេញសត្វហើយសំរាប់បានទៅសុំឆ្កែនឹងនៅលង់ច័ន្ទ
មកហាសចាសនិយាយទៅលង់ច័ន្ទនឹងគឺនៅប្រទេស ថៃ
ហាសហើយវាបានទៅសុំគេមកនឹងគឺពួកវានឹងតាំងពីតូចហើយវាប៉ៅតែទឹកដោះ
គោនោះទេចាសហើយនិយាយទៅសំរាប់មនុស្សដែលចំម្លែកនឹងគឺកុំចូលមកអីហា
សចាសហើយដល់តែស្គាល់ឈ្មោះហើយបានហៅអោយចំបាននឹងបានអោយចូល
ចឹងហាសចាសហើយប្រសិនជាអត់បានស្គាល់ឈ្មោះរបស់វានោះទេគឺវាអោយចូល
នោះទេហើយប្រសិនជាយើងនៅតែចូលទៀតនឹងគឺវានឹងក្រហឹមដាក់យើងតែម្តង
ហាសចាសហើយនិយាយទៅគឺយើងចង់អោយពួកវានឹងអោយទៅគេនឹងពាងង
ទៅហើយហាសចាសពីព្រោះអីនឹងគឺវាបានកាំគេនឹងពាងងដែលចឹងហាសពីព្រោះ
អីនឹងគឺវាមិនបានស្គាល់ឈ្មោះរបស់វាចឹងហាសហើយសំរាប់មួយនឹងគឺវាឈ្មោះមី
កៅហ៊ូ ហើយសំរាប់មួយទៀតនឹងគឺវាឈ្មោះថា មីកាជ្រួន
ហាសហើយអោយតែយើងហៅឈ្មោះរបស់វានឹងគឺយើងអាចចូលមកលេងវាបានចឹ
ងហាសចាសហើយប្រសិនជាយើងមិនហៅឈ្មោះរបស់វានោះទេគឺយើងមិនអាចនឹ
ងចូលមកបានោះទេចាសហើយសំរាប់សព្វថ្ងៃនឹងគឺរបស់របបនឹងគឺមានតែប៉ុន
នឹងចឹងហាសចាសហើយគ្មាននាក់ណានឹងហ៊ានចូលមកនោះទេហើយប្រសិនជា
ក្រៅពីផ្ទះរបស់ខ្ញុំនឹងគឺគាត់បានលួចអស់ហើយចឹងហាសចាសពីព្រោះអីនឹងផ្ទះរប
សខ្ញុំនឹងគឺគ្មានអ្វីនឹងបានបិទបាំងនឹងគេនោះទេចាសហើយសំរាប់ឆ្កែដែលតឿៗ
ហើយនឹងតូចនឹងក៏ពួកវានឹងខ្លាំងដែលចឹងហាសចាសហើយសំរាប់ឆ្កែមួយនេះគឺ
ជាឆ្កែដែលដេញសត្វចឹងហាសហើយសំរាប់ឆ្កែទាំងអស់នេះវិញគឺជាឆ្កែដែលយាម
ហើយពួកវានឹងបានបបួលគ្នានឹងយាមហើយនឹងព្រុះពេញនឹងចឹងនាក់ដែលពួក
វាមិនស្គាល់ចឹងហាសចាសហើយទាល់តែម្ចាស់ផ្ទះនឹងគឺអោយពួកវានឹងចូលផ្ទះបា
ននាក់ផ្សេងនឹងបានដើរចូលមកក្បួចចឹងហាសចាសនិយាយទៅគឺពួកវានឹងគឺស្លា
តខ្លាំងណាស់ហើយគ្មាននាក់នឹងហ៊ានចូលផ្ទះបាននោះទេចាស ៕
កៈ
បាទហើយចឹងបានន័យថាពីផ្ទះនេះរហូតដល់ផ្ទះនោះនឹងគឺជាក្រុមគ្រួសាររបស់
លោកយាយទាំងអស់មែនដែលរឺទេលោកយាយ ???

ខ៖
ចាសៗនិយាយទៅសំរាប់ផ្ទះនេះហើហយរហូតដល់ផ្ទះនោះនឹងគឺជាគ្រួសាររបស់ខ្ញុំទាំងអស់ចឹងហាសចាសហើយសំរាប់ម្តុំផ្ទះរបស់ខ្ញុំនឹងគឺគ្មាននាក់ណាចូលមកចុះនោះទេហើយប្រសិនជាចង់មកធ្វើបាបនឹងគឺធ្វើបាបមិនបាននោះទេចាសហើយដើរមកនឹងគឺដើរមករកអ្វីដែលហើយសំរាប់ខ្ញុំបានប្រកាសថាប្រសិនជាឆ្កែរបស់ខ្ញុំនឹងបានកាំនឹងគឺខ្ញុំមិនបានចាក់ថ្នាំអោយនោះទេហើយប្រសិនជានាក់ដែលដើរមកនឹងគឺនៅកណ្តាលផ្លូវនឹងហើយពួកវានឹងបានទៅកាំនឹងគឺខ្ញុំនឹងចាក់ថ្នាំអោយចឹងហាសចាសហើយប្រសិនជាចូលមកដល់ផ្ទះរបស់ខ្ញុំនឹងគឺខ្ញុំមិនចាក់អោយនោះទេចាសនិយាយទៅគឺខ្ញុំមិនបានចាក់អោយនោះទេចាស ៕
ក៖ បាទនិយាយទៅគឺត្រូវហើយគឺយើងត្រូវតែការពារចឹងហើយ
ហើយនិយាយទៅគឺការរស់នៅនឹងគឺវាមានភាពសុខសាន្តចឹងទៅហើយនឹងរស់នៅក្នុងសង្គមនឹងគឺនៅក្នុងក្រុមគ្រួសារនឹងហើយយើងមានភាពចិត្តល្អចឹងគឺយើងមានភាពល្អជាងមែនដែលរឺទេលោកយាយ ???
ខ៖
ចាសនិយាយទៅគឺត្រូវហើយសំរាប់នាក់ខ្លះនឹងនៅពេលដែលយើងនឹងក្រហាសគឺពួកគេនឹងចង់តែជាន់យើងចឹងហាសចាស ៕
ក៖
បាទហើយចឹងខ្ញុំចង់សួរលោកយាយតិចថានៅក្នុងសម័យលន់ណលនឹងថាតើពួកគេមានសង្គ្រាមដែលរឺទេក៏នៅក្នុងជំនាន់នឹងប្រជាជនបានរស់នៅតាមធម្មតាដូចនៅក្នុងសម័យនេះដែលទៅរឺទេលោកយាយ ???
ខ៖
ចាសនិយាយទៅគឺអត់នោះទេចាសគឺគេមានសង្គ្រាមហាសពីព្រោះអីនឹងគឺគេបានទំលាក់រដ្ឋប្រហារហើយមានសង្គ្រាមហាសចាស ៕
ក៖
បាទចឹងបានន័យថាសំរាប់នៅក្នុងជំនាន់នឹងគឺអត់មានសង្គ្រាមនោះទេមែនដែលរឺទេលោកយាយ ???
ខ៖ ចាសនិយាយទៅគឺមានសង្គ្រាមហាសសំរាប់ខ្មែរក្រហមនឹង
ហើយនឹងប៉ុលពតនឹងលន់ណលនឹងគឺពួកគេនឹងវៃគ្នានឹងឯងចឹងហាសចាសហើយសំរាប់ជំនាន់នឹងគឺគេបានវៃគ្នាបែកមុំបែកដីពោញនឹងចឹងហាសចាសនិយាយទៅវៃគ្នានឹងគឺខ្លាំងណាស់ហើយសំរាប់មួយសំរោងក្តោងនឹងម្ខាងនឹងហាសចាសនិយយាទៅគឺនៅក្នុងជំនាន់នឹងគឺមានសង្គ្រាមហាសចាសសំរាប់នាក់ទំលាក់លន់ណនហើយនឹងរដ្ឋប្រហារនឹងគឺមានសង្គ្រាមហើយចឹងហាសចាស ៕
ក៖
បាទហើយចឹងនៅពេលដែលជំនាន់នឹងគឺគេបានធ្វើសង្គ្រាមចឹងប្រជាជននៅក្នុងជំនាន់នឹងគឺមិនពួកគាត់មានភាពពិបាកហើយមែនដែលរឺទេលោកយាយ ???
ខ៖
ចាសនិយាយទៅគឺនៅក្នុងជំនាន់នឹងគឺម្នាក់ៗនឹងគឺគេរកតែមានក្តីសុខចឹងហាសហើយសំរាប់នាក់ណាដែលគេបានទំលាក់គ្រាប់នៅទីកន្លែងណានឹងក៏គ្មាននាក់ណាបានដឹងដែលចឹងហាសចាសអារក្តសំរោងនៅក្រោយម្ខាងរបស់យើងនឹងហើយសំរាប់នៅវត្តក្តួលយើងនឹងអូនឯងមានបានស្គាល់ដែលរឺទែ ???
ក៖ បាទនិយយាទៅគឺអត់ទាន់បានស្គាល់នោះទេលោកយាយ ???
ខ៖
ហើយនិយាយទៅសំរាប់វត្តរបស់យើងនឹងគឺនៅខាងនោះទេហើយសំរាប់ម៉ូតូរបស់យើងនឹងមិននៅខាងនោះចឹងហាសហើយសំរាប់ទូតនឹងនៅខាងនេះហើយសំរាប់ខ្មែរក្រហមនឹងគឺនៅខាងនោះទេហើយសំរាប់ទាំង២នឹងគឺបាញ់គ្នាពេញនឹងចឹងហាសចាសនិយាយទៅគឺពួកវានឹងគឺនៅម្នាក់មួយចំហៀងចឹងហាសចាស ៕
ក៖
បាទហើយចឹងសំរាប់នៅក្នុងជំនាន់នឹងថាតើគេមានទំលាក់គ្រាប់បែកតាមយន្តហោះដែលរឺទេលោកយាយ ???
ខ៖
ចាសនិយាយទៅគឺមានណាស់ក្មួយលោកអើយនិយយាទៅគឺពួកវានឹងបានទំលាក់រហូតចឹងហើយសំរាប់ខ្ញុំបានទៅពួននៅត្រង់សេគឺមានមនុស្សនឹងបានរត់ចូលតែត្រង់សេនឹងចឹងហាសហើយសំរាប់មាននាក់ខ្លះនឹងគឺគេបានស្លាប់ហើយសំរាប់នា

ក់ខ្លះទៀតនឹងក៏គេបាននៅរស់ចឹងហាសហើយនិយាយទៅគឺរស់តាមព្រៃនរិសានាចឹងទៅហាសចាសហើយសំរាប់ក្រួសាររបស់ខ្ញុំនឹងគឺយើងទាំងអស់គ្នានឹងគឺមិនអីនោះទេចាសហើយនិយាយទៅគឺអត់អីចឹងហាសហើយមាននាក់ខ្លះនឹងគឺគេបានស្លាប់ដែលចឹងហាសហើយនិយាយទៅគឺនៅក្នុងជំនាន់ដើមនឹងគឺគេបានហៅពួកវាថា អាស្លាប កាត់ ហើយអាមិច
អីចឹងទៅហាសចាសនឹងហើយនៅពេលដែលយើងនឹងបានឃើញពួកវានឹងយើងបានរត់ចូលត្រង់សេហើយហើយសំរាប់ត្រង់សេនឹងគឺយើងមានគ្រាប់ទីកន្លែងចឹងហាសហើយសំរាប់ខ្ញុំគឺមិនដែលមានអ្វីកើតឡើងនោះទេហើយសំរាប់ខ្ញុំគ្រាន់តែអង្គុយនៅចាំមើលយន្តហោះនោះទេចាស ៕
ក៖
បានហើយចឹងប្រសិនជាយើងបានរត់ចូលត្រង់សេនឹងប្រហែលជាយើងមិនអីនោះទេមែនដែលរឺទេលោកយាយ ???
ខ៖
ចាសនិយាយទៅប្រសិណជាយើងបានរត់ចូលត្រង់សេនឹងគឺយើងមិនអីនោះទេចាសតែប្រសិនជាពួកវានឹងបានដាក់ចំនៅមាត់រណ្តៅនឹងគឺយើងស្លាប់ទាំងអស់គ្នាដែលចឹងហាសចាសនិយាយទៅគឺដូចថានឹងគឺជាកម្មផលចឹងហាសហើយសំរាប់យើងរកនិយាយមិនបានចឹងហាសចាស
ហើយសំរាប់មាននាក់ខ្លះនឹងគឺគេបានស្លាប់តែម្តាយហើយនឹងកូនចឹងហាសហើយពីព្រោះអីនឹងនៅពេលដែលយយើងនឹងបានមើលពីលើនឹងគឺវាចេះតែឃើញចឹងហាសចាសពួកវាបានដាក់មួយគ្រាប់នឹងនៅកន្លែងត្រង់សេនឹងគឺបានស្លាប់ទាំងអស់នឹងចឹងហាសចាស ៕
ក៖ បានចឹងនៅពេលដែលពួកវាបានគ្រាប់ចឹងគឺយើងបានដូចសាច់ជ្រូកដុសចឹងហើយសំរាប់ពេលខ្លះនឹងគឺដូចលោកយាយបានមានប្រសាសន៍ចឹងជីវិតរបស់យើងនឹងគឺយើងមើលមិនឃើញនោះទេមែនដែលរឺទេលោកយាយ ???
ខ៖
ចាសនិយាយទៅគឺយើងមើលមិនឃើញនោះទេហើយប្រសិនជាយើងបានធ្វើជាអំពើល្អទៅវិញនឹងគឺខ្ញុំបានជួបតែមនុស្សល្អដែលចឹងហាសហើយប្រសិនជាខ្លះបានធ្វើអាក្រក់វិញនឹងគឺខ្ញុំបានស្លាប់ឃួរបាត់ហើយស្អានពេលបានមកនៅដល់ពេលល្ងាចនឹងនោះទេហាសចាសហើយសំរាប់ខ្ញុំបានធ្វើបានល្អខ្លាំងណាស់ហើយសំរាប់ខ្ញុំចង់ប្រាប់អូនឯងនឹងអោយបានត្រង់នៅក្នុងជំនាន់នឹងគឺខ្ញុំបានធ្វើជាមេចុងភៅនឹងហើយសំរាប់ប្តីរបស់ខ្ញុំនឹងគឺគាត់បានធ្វើជាប្រធានក្រុមដែលហាសចាសដូចថាប្រសិនជាយើងធ្វើជាមេចឹងហើយយើងបានកាន់កាប់មេ ៥០
ខ្នងអីចឹងទៅហាសចាសគឺយើងបានមើលការខុសត្រូវមេ ៥០
ខ្នងអីចឹងទៅហាសចាសនឹងសំរាប់ក្រុមរបស់យើងនឹងតែសំរាប់ខ្ញុំនឹងគឺខ្ញុំបានធ្វើល្អខ្លាំងណាស់ចាសហើយចាប់ពីទន្លេរខ្សែក្រហមនឹងហាសហើយសំរាប់មនុស្សដែលគេបានចងដាក់ខ្សែក្រហមហើយបានដាក់នឹងគឺគេយកទៅរៃចោលហើយហើយនៅពេលដែលគេបានមកចឹងទៅគឺខ្ញុំបានលេងអោយទៅលេងប្រពន្ធហើយអោយប្រពន្ធនឹងបានទៅដាំបាយដើម្បីទៅទទួលកម្មករនឹងចំនួន ២០
នាក់ហាសចាសហើយធ្វើយ៉ាងមិចអោយពួកនឹងអោយបានស៊ីអោយបានឆ្អែតចឹងហើយបានគេបានយកមករៃហាសចាសហើយសំរាប់ខ្ញុំក៏បានសួរពួកគេដែលត្រូវនឹងយករៃនឹងថាសំរាប់មិត្តទាំងអស់គ្នានឹងមានកំហុសអ្វីបានជាយកទៅរៃចោលចឹងហើយសំរាប់នាក់ខ្លះនឹងគឺគេបានឆ្លើយប្រាប់យើងនឹងថាពួកគេនឹងបានធ្វើខុសសិល្បធម៌ចឹងហាសចាសនឹងគឺយើងបាននិយាយរកខុសហើយនឹងត្រូវចឹងហាសចាសហើយសំរាប់ជំនាន់នឹងគឺអោយយើងនឹងទៅជួយហើយយើងជួយយ៉ាងមិចបាន
ពីព្រោះអីនឹងគឺគេបានរកនេសាទអោយយើងនឹងបានធ្វើចឹងហាសចាសហើយខ្ញុំបាននិយាយចឹងហាសហើយសំរាប់យើងគួរតែអត់អន់អោយគ្នានឹងយ៉ាងតិចណាស់ក៏មាន ២០
នាក់ដែលចឹងហាសចាសហើយនិយាយទៅគឺខ្ញុំបានជួយគេនឹងបានច្រើននាក់ខ្លាំងណាស់ចាស
ហើយខ្ញុំបានប្រាប់គេថាកុំធ្វើបាបគេអីលូវនឹងគឺយើងកសាងពួកគាត់នឹងអោយជួយការងាររបស់យើងវិញចឹងហាសចាស
ហើយនឹងបានកំណត់ត្រីអោយគេនឹងនៅក្នុងមួយខែនឹងអោយត្រីទៅកាន់គេនឹ

ដចំនួន
ប៉ុន្មានគោនអោយគេហើយប្រសិនជាមិនគ្រប់គោនអោយយើងធ្វើយ៉ាងមិចហើយសំរាប់ខ្ញុំបាននិយាយគ្រប់សព្វទាំងអស់ហើយចឹងហាសចាសហើយសំរាប់អូនឯងនឹងគឺទុក្ខនៅមួយកន្លែងចឹងហាសចាសហើយក៏ពួកវានឹងបានយល់ព្រមអោយកសាងហើយអោយជួយទុក្ខដាក់មោងអោយពួកវាចឹងហាសចាស
ហើយពួកគេនឹងក៏បានធ្វើការងារទាំងអស់ចឹងទៅហើយសំរាប់ឈ្មួបរបស់គេនឹងនៅតែគានដានយើងទៀតហើយមានអ្វីពួកគេនឹងនៅកែទំលាប់នឹងចោលចឹងហាសចាសហើយសំរាប់ខ្ញុំបានជួយគេនឹងបានច្រើនណាស់ហើយកុំឃើញពួកយើងចឹងគឺយើងបានជួយគេនឹងបានច្រើនខ្លាំងណាស់ចាសហើយរហូតមកបានវៀតណាមគេបានចូលមកហើយយើងមានជីវិតហើយបានទៅអាមេរិច
ហើយនឹកឃើញថាគានេះហើយនឹងយាយនេះបានជួយយើងនឹងគឺគ្មាននោះទេចាសពីព្រោះអីនឹងគេបានរួចខ្លួនរបស់គេអស់ហើយចឹងហាសចាសហើយសំរាប់មានច្រើនខ្លាំងណាស់នាក់ដែលនៅខាងពោធិសាត់នឹងហាសចាសនិយាយទៅគឺអាឆេងហើយនឹងមីកាឆាយអីនឹងគឺសុទ្ធតែខ្ញុំនឹងជានាក់ជួយចឹងហាសហើយសំរាប់គេបានលុយមកពីនាក់នៅខាងអាមេរិចនឹងផ្ញើអោយតាង៉ាត់នឹងគឺគេបានផ្ញើ ៥០០ ដុល្លា
ដោយសារតែគេបានមកជួយយើងចឹងហាសចាសហើយអោយយើងនឹងបានចាយបាន ប្អូន ទៅ ដប
ដុល្លាចឹងទៅហាសចាសហើយចឹងបានខ្ញុំថានៅពេលដែលយើងបានធ្វើល្អនឹងគឺយើងបានទទួលបានផលនឹងក៏ល្អដែលចឹងហាសចាសហើយសំរាប់នាក់នឹងគឺគាត់មិនបានដឹងតែមាននាក់ដែលផ្សេងនឹងគឺគេបានដឹងចឹងហាសចាស ៕
ក៖ បាទហើយចឹងមិនជាអ្វីនោះទេប្រសិនជាគេមើលមិនឃើញយើងនោះទេប្រហែលជាមាននាក់ដែលផ្សេងដែលយើងបានជួយនឹងគឺគេអាចជួយយើងនៅថ្ងៃណាមួយជាមិនខាននោះទេពីព្រោះអីនឹងបុណ្យដែលយើងបានធ្វើនឹងគឺនៅតែមាននៅពេលដែលយើងបានជួយគេមែនដែលរឺទេលោកយាយ ???
ខ៖
ចាសនិយាយទៅគឺកូនហើយនឹងម្តាយហើយខ្ញុំនិយាយអោយអស់តែម្តងចឹងទៅហាសចាសគ្រាន់តែញ្ញាត្តិនឹងគឺបានជួយគាត់នឹងរាប់ពាន់ដុល្លា
ពីព្រោះអីនឹងម្នាក់បានជួយគាត់ម្នាក់ ៥០០០០ នាក់ខ្លះនឹងក៏បាន ៣០០០០ នៅពេលដែលគាត់បានឈឺលើកមុននឹងហើយរយៈពេល ៣ ឆ្នាំនឹងបានគាត់បានធ្លាក់ឈឺធ្ងន់ម្តងទៀតចឹងហាសចាសហើយសំរាប់ញ្ញាត្តិគឺបានជួយគាត់ទាំងអស់គ្នាបានចេញលុយរបស់ខ្លួនអស់មួយរៀលនោះទេចាសមាននាក់ខ្លះនឹងគឺបានអោយគាត់នឹង ៥០០០០០
ហើយមាននាក់ខ្លះនឹងអោយគាត់ ១០០០០០
ហើយនឹងមាននាក់ខ្លះនឹងអោយគាត់ ៥០ ដុល្លា
ហើយក៏មាននាក់ខ្លះនឹងជួយគាត់រហូតទៅដល់ ១០០
ដុល្លាដែលគាត់បានធ្វើអំពើល្អចឹងហាសចាសពីព្រោះអីនឹងនៅពេលដែលមាននាក់ស្លាប់នឹងហើយមានបុណ្យទានអីទាំងអស់នឹងគឺគាត់បានទៅជួយរៀបទាំងអស់ចឹងហាសចាសនក្នុងក្រុមវត្តលៀបនឹងសំរាប់លោកគ្រូនឹងក៏គាត់បានទៅជួយដែលហាសចាសហើយសំរាប់គាត់បានជាអស់រយៈពេលនឹង៣ឆ្នាំហើយនៅពេលដែលគាត់បានធ្លាក់ខ្លួនឈឺនឹងគឺអស់៤ឆ្នាំហើយចឹងហាសចាសនិយាយទៅគឺគាត់ឈឺនឹងគឺគាត់ទន់តែម្តងហើយគ្មានអីនោះទេនិយាយទៅគឺគាត់ទន់ទៅតែម្តងហាសហើយសំរាប់លោកគ្រូគាត់បានបង្រៀននឹងនៅកន្លែងនេះហើយនឹងមានញ្ញាតិជួយចឹងហាសចាសមានាក់ខ្លះអោយ ៥០០០០រៀល ហើយនាក់ខ្លះ ៤០០០០ ទៅ ៣០០០០ ទៅ ២០០០០ ទៅ
និយាយទៅអោយមកតគ្នាដូចចូលបុណ្យខ្មោចចឹងហាសចាសហើយនៅពេលដែលយើងបានលុយទាំងអស់នឹងចឹងទៅគឺយើងចេះតែសន្សំហើយចឹងហាសហើយយើងចេះតែទៅទិញអាហារកំប៉ុងអោយគាត់ហូបចឹងទៅគឺអត់ហ៊ាននឹងចាយអីផ្តេសផ្តាសនោះទេចាសហើយសំរាប់អាហារមួយកំប៉ុងនឹងនៅពេលដែលយើងនឹងទៅទិញដល់កន្លែងនឹងគឺ ១៥០០០
រៀលចឹងទៅហើយប្រសិនជាយើងទៅទិញនៅពេទ្យនឹងគឺមួយកំប៉ុង ១៨០០០រៀលចឹងទៅហាសចាសនឹងគឺជាអាហារកំប៉ុងដែលតូចៗប៉ុនៗចឹងហាសចាសដូចថាខ្ញុំបានជួយគេនឹងតាំងពីជំនាន់ណាចឹងហើយដល់ពេលដែលគេបាន

មកជួយយើងវិញចឹងហាសទោះបីជាវាគិចរឺក៍ច្រើនក៍ដោយចឹងហាសចាសនិយាយទៅគឺគេចេះតែជួយយើងនឹងបានតិចៗចឹងហាសចាសហើយសំរាប់ម្សិលម្សាញនឹងគឺខ្ញុំអត់បានដើរទៅមុខនោះទេនៅពេលដែលខ្ញុំបានទៅនឹងគឺគេបានអោយលុយខ្ញុំនឹងហើយគាត់ថាជួយខ្ញុំនឹង ២០០០០ រៀល ហើយនឹងនាក់ខ្លះនឹងអោយបាន ១០០០០រៀលចឹងទៅហាសចាសហើយខ្ញុំបាននិយាយថាប្រសិនជាអោយខ្ញុំចឹងមិនខ្លួនឯងនឹងអត់ហើយ
ហើយគេបាននិយាយថាទេបងយកវាទៅទុក្ខសំរាប់ទិញអ្វី២នាក់បងពិសារចឹងហាសចាសហើយសំរាប់បងគឺគាត់ពិសារមិនបាននោះទេនៅពេលដែលគេបានអោយខ្ញុំនឹងគឺគេបានអោយពរខ្ញុំទៀតចឹងហាសហើយចឹងបានថាសំរាប់បុណ្យកុសលរបស់យើងនឹងមានណាស់កូនហើយប្រសិនជាយើងដាច់ហើយគឺមាននាក់ដែលយកមកអោយហើយមានម្នាក់ ២០០០០ រៀល ៣០០០០រៀល ចឹងទៅហាសចាស ៕
ក៖
បានហើយចឹងសំរាប់គាត់នេះជាកូនរបស់លោកយាយដែលមែនដែលរឺទេលោកយាយ ???
ខ៖ ចាសនិយាយទៅគឺអត់នោះទេគឺគាត់ជាប្អូនរបស់ខ្ញុំនោះទេចាស ៕
ក៖
បានចឹងមិនអីនោះទេហើយចឹងសង្ឃឹមថាសំរាប់លោកយាយនឹងទទួនបានផលបុណ្យបន្តែមទៀតហើយនឹងបានច្រើនជាងនឹងហើយនឹងបានទទួលបានពីញ្ញាតិដិតខាងណាលោកយាយ ???
ខ៖
ចាសនិយាយទៅសំរាប់ញ្ញាតិដិតខាងនឹងគឺគ្មាននាក់ណាដែលបានមកស្អប់ខ្ញុំនោះទេហើយសំរាប់នាក់ខ្លះនឹងគឺគេបានយកលុយ ៣០០០
ខ្មែរមកអោយខ្ញុំនឹងក៍មានដែលចឹងហាសចាសហើយគេអោយនឹងយកទៅទិញអីនឹងសំរាប់ពិសារចឹងទៅហើយសំរាប់នាក់ខ្លះនឹងគាត់អោយ
៥០០០រៀលសំរាប់ទិញអ្វីសំរាប់ពិសារចឹងទៅហាសចាស
ហើយសំរាប់ខ្ញុំចង់និយាយថាចេះអោយតែដល់ថ្ងៃសល៍នឹងគឺមានតែខ្ញុំនោះទេនៅក្នុងវត្តលៀបនឹងគឺខ្ញុំបានដើររីលុយគ្នាមានបងៗខ្លះណាស់នឹងគឺអោយ ៥០០ រឺ ៣០០ អីទាំងអស់នឹងគឺខ្ញុំបានដើរបិនរហូតចឹងហាសចាសចាប់ពីម៉ោង ៧ ព្រឹករហូត ដល់ ៥
ល្ងាចនឹងបានខ្ញុំបានចូលមកផ្ទះវិញចឹងហាសហើយសំរាប់ពេលខ្លះនឹងគឺខ្ញុំបាន ១៥០០០០រៀលចឹងទៅហាសចាសហើយនៅពេលដែលបានលុយទាំងអស់នឹងហើយគឺលោកគាត់បានអោយខ្ញុំនឹងជានាក់ចាប់ចែងអោយខ្ញុំនឹងទៅទិញម្ហូបសំរាប់ឆាន់រួមចឹងទៅហាសចាសនឹងសំរាប់តែថ្ងៃស៍ល
ហើយផុតពីថ្ងៃសល៍នឹងគឺលោកគាត់អាចចេញទៅរកឆាន់បានដោយខ្លួនឯងចឹងហាសចាសនិយាយទៅគឺអោយតែថ្ងៃសល៍ចឹងហាសហើយសំរាប់នៅតែវត្តលៀបយើងនឹងហាសចាសហើយសំរាប់ខាងនោះគឺជាវត្តរំដួល
ហើយអោយតែថ្ងៃសល៍នឹងគឺខ្ញុំតែងតែដើរបិនបាតរហូតចឹងទៅចេះតែទៅជុំវិញនៅក្នុងវត្តលៀបនឹងចឹងទៅហាសចាសជួនកាលនឹងគឺយើងបាន ១៤០០០០រៀលចឹងទៅហើយសំរាប់ញ្ញាតិខ្លះនឹងគឺគេបានដឹងថាយើងជានាក់ដែលបានធ្វើបុណ្យហាសចាសមានពេលខ្លះនឹងគឺយើងបានរហូតទៅដល់
១៦០០០០រៀលចឹងទៅពីព្រោះអីនឹងគឺមានពេលខ្លះនឹងគឺគេបានបិទទ្វាផ្ទះនៅពេលដែលគេមិនបាននៅចឹងហាសចាសជួនកាលនឹងបាន ១៣០០០០០ ទៅ ១៦០០០០រៀលចឹងទៅហាសហើយនៅពេលដែលបានហើយចឹងគឺយើងបានយកទាំងអស់នឹងបានទៅទិញម្ហូបហើយហូបរួមគ្នាចឹងទៅហាសចាសហើយបានម្ហូប ២ ទៅ៣
មុខចឹងទៅហើយសំរាប់អង្ករនឹងគឺគេបានជួយយើងចឹងហាសចឹងហាសចាសហើយសំរាប់ដាំបាយនឹងគឺគេបានដាក់ជាមួយនឹងស្វាយសំរាប់ហូបចឹងហាសចាស ៕
ក៖
បានហើយចឹងបានន័យថាសំរាប់មួយសប្តាហ៍នឹងគឺលោកយាយបានធ្វើវាបានម្តងមែនដែលរឺទេលោកយាយា ???
ខ៖ ចាស។
និយាយទៅគឺយើងចេះតែដើរហើយសំរាប់យើងបានអោយកូននឹងអោយនៅមើលឪពុកចឹងទៅហាសចាសហើយយើងដើរទៅរកហម្ហូបអោយលោកចឹងហាស ៕

កៈ
បាទនិយាយទៅគីម្យ៉ាងដែលសំរាប់លោកយាយដើរកហើយនឹងសន្សំផលបុណ្យសំរាប់ទុក្ខអោយខ្លួនឯងផងហើយនឹងសំរាប់កូនចៅជំនាន់ក្រោយរបស់លោកយាយផងដើម្បីអោយគាត់បានផលបុណ្យបានពីលោកយាយបន្ទាប់ៗទៀតមែនដែលលឺទេលោកយាយ ???
ខៈ ចាសៗ ៕
កៈ
បាទចឹងអរគុណច្រើនមែនទែនលោកយាយដែលបានចែកចាយពីបទពីសោធន៍របស់លោកយាយច្រើន ៕
ខៈ
ចាសនិយាយទៅអូនឯងអាចទៅសួរនាក់ដែលនៅជិតខាងបានសំរាប់ខ្ញុំមិនដែលធ្វើអាក្រក់នោះទេហើយសំរាប់ខ្សែស្រឡាយរបស់ខ្ញុំនៅទីកន្លែងនឹងគឺរែងខ្លាំងណាស់ចាស ៕
កៈ
បាទហើយចឹងអរគុណច្រើនណាលោកយាយដែលបានចែកចាយពីបទពិសោធន៍របស់លោកយាយសំរាប់ថ្ងៃនឹងផងដែលហើយសំរាប់ថ្ងៃនឹងគឺខ្ញុំសប្បាយចិត្តចឹងប្រហែលជាតិចទៀតនឹងគឺខ្ញុំចង់ទៅមុខទៀតចឹងហាសហើយចឹងអរគុណច្រើនលោកយាយហើយសំរាប់ថ្ងៃនឹងគឺខ្ញុំសប្បាយដែលបានជួបលោកយាយហើយជាថ្ងៃទី ៣១ ខែ ៥ ឆ្នាំ ២០១៩ ហើយសំរាប់ខ្ញុំឈ្មោះ គីម ម៉េង
ហើយសំរាប់ឈ្មោះហៅក្រៅខ្ញុំឈ្មោះម៉េង ហើយចឹងអរគុណច្រើនលោកយាយ ៕